**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ធំ**

**សាលក្រមព្រហ្មទណ្ឌលេខៈ ១១ "ញ"**
ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤
**សំណុំរឿងព្រហ្មទណ្ឌលេខៈ ៥១៧**
ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣
**សំណុំរឿងស៊ើបសួរលេខៈ ២៦៧**
ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២៣
**សំណុំរឿងជំនុំជម្រះលេខៈ ៤៦៣**
ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣

**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកំពង់ធំ**

បានបើកសវនាការជាសាធារណៈនាថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤
នៅសវនាការនៃសាលាដំបូងខេត្តកំពង់ធំ
វេលាម៉ោង ៩ និង ០០នាទី ព្រឹក សាលសវនាការទី១
ប្រកាសសាលក្រមនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤។
ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោក [redacted] ជាចៅក្រមប្រឹក្សាជំនុំជម្រះ
-លោកស្រី [redacted] ជាចៅក្រមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជី

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៥១៧ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ ដែលមាន៖

ជនជាប់ចោទ៖

ឈ្មោះ [redacted]សុខខេង ហៅ កំរី ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើតភូមិទួល [redacted] ខេត្តកំពង់ចាម និងមានទីលំនៅបច្ចុប្បន្នមុនពេលឃាត់ខ្លួនរស់នៅភូមិ [redacted] ខេត្តកំពង់ធំ មុខរបរ កម្មករ ឪពុកឈ្មោះ [redacted] សំណាង (រស់) ម្តាយឈ្មោះ [redacted] សុខឃាង (រស់) និងប្រពន្ធឈ្មោះ [redacted] ស៊ីម៉ាស់ មានកូនចំនួន០៣នាក់ កម្រិតវប្បធម៌៖ថ្នាក់ទី០៦ ទោសពីមុន៖ គ្មាន។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៥០ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ។

ជាប់ចោទពីបទ៖ "ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅចំណុចស្ពានអូរទឹកថ្លា ភូមិបង្គីតាំងរ៉េន ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១៧ និង ០០នាទី បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២។



Scanned with CamScanner

ដែលមានលោកមេធាវី [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យស្ថិតនៅផ្ទះលេខ ៣០ ផ្លូវលេខ ៥៨៦ ភូមិ១៣ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

## អង្គហេតុនៃរឿងមានដូចតទៅ៖

កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១៧ និង ០០នាទី នៅចំណុចស្ពានអូរទឹកថ្លា ភូមិបង្គីតាំងរែន ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ កម្លាំងមន្ទីរស្រាវជ្រាវ និងបង្ក្រាបបទល្មើស នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកំពង់ធំ បានសហការជាមួយកម្លាំងកងរាជអាវុធហត្ថស្រុកបារាយណ៍ និងកម្លាំងកងរាជអាវុធហត្ថស្រុកសន្ទុក បានបង្ក្រាបបទល្មើសគ្រឿងញៀន ដោយបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី ភេទប្រុស អាយុ៣៦ឆ្នាំ។ ជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី ភេទប្រុស អាយុ៣៦ឆ្នាំ បានទាក់ទងទិញថ្នាំញៀន តាមទូរស័ព្ទពីអ្នកលក់មិនស្គាល់ឈ្មោះ ដោយទិញម្តងៗ ចន្លោះពី ៣០.០០០ (សាមសិបម៉ឺន) រៀល ទៅ ១.២០០.០០០ (មួយលានពីរសែន) រៀល។ ពេលទិញថ្នាំញៀនរាល់ដង ជនជាប់ចោទបានជិះម៉ូតូទៅយកថ្នាំញៀននៅជិតទួលពន្លៃ ខេត្តត្បូងឃ្មុំ។ ពេលបានថ្នាំញៀន ជនជាប់ចោទបានយកថ្នាំញៀនទុកប្រើប្រាស់ខ្លះ និងរំលែកលក់បន្តឱ្យកម្មករជៀរជ័រកៅស៊ូខ្លះ ក្នុងតម្លៃ មួយកញ្ចប់ ពី ២០.០០០ (ពីរម៉ឺន) រៀល ទៅ ២០០.០០០ (ម្ភៃម៉ឺន) រៀល។ នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ ក៏មានគេទាក់ទងទិញថ្នាំញៀនពីជនជាប់ចោទចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) រៀល ហើយនៅពេលជនជាប់ចោទយកថ្នាំញៀនទៅឱ្យគេ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ជនជាប់ចោទបានចាប់ផ្តើមលក់ថ្នាំញៀនឱ្យកម្មករជៀរជ័រកៅស៊ូ ចាប់តាំងពីអំឡុងខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃត្រូវបានឃាត់ខ្លួន។ នៅពេលឃាត់ខ្លួនសមត្ថកិច្ចបានដកហូតពីខ្លួននូវ ថ្នាំញៀនចំនួន ១៨ កញ្ចប់ ទម្ងន់ ១៧,២២ក្រាម ទូរស័ព្ទ០១គ្រឿង ម៉ូតូចំនួន០១គ្រឿង និងសម្ភារៈវេចខ្ចប់ថ្នាំញៀនមួយចំនួន។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤២១/២០២៣ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ។

-បានឃើញ ដីកាដំណោះស្រាយលេខ ៣៦៤៥ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ។

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ៦០៨ ត.ព្រ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកំពង់ធំ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សុខខេង មានវត្តមាន។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មានវត្តមាន។

-មន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] គឹមលេង មានវត្តមាន។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុខខេង បានឆ្លើយនាពេលសវនាការថា ខ្លួនទទួលស្គាល់ការចោទប្រកាន់របស់តំណាងអយ្យការ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនរយៈពេល៣ឆ្នាំមកហើយ។ ខ្លួនមិនដែលធ្លាប់ទទួលវិធានការបន្សាបថ្នាំញៀននោះទេ។ នៅអំឡុងដើមឆ្នាំ២០២៣ ខ្លួនបានស្គាល់លេខទូរស័ព្ទរបស់អ្នកលក់ថ្នាំញៀនមិនស្គាល់ឈ្មោះម្នាក់ នៅទួលពន្លៃ ខេត្តត្បូងឃ្មុំ។ ខ្លួនបានទាក់ទងទិញថ្នាំញៀនតាមទូរស័ព្ទពីអ្នកលក់នេះបានចំនួន ៦ដង ដោយទិញម្តងៗចន្លោះពី ៣០.០០០ (សាមសិបម៉ឺន) រៀល ទៅ



Scanned with CamScanner

១.២០០.០០០ (មួយលានពីរសែន) រៀល ពេលទិញថ្នាំញៀនរាល់ដងខ្លួន បានជិះម៉ូតូទៅយកថ្នាំញៀន នៅជិតទួលពន្លៃខេត្តត្បូងឃ្មុំ។ ពេលបានថ្នាំញៀនខ្លួនបានយកថ្នាំ ញៀនទុកប្រើប្រាស់ខ្លះ និងរំលែកលក់បន្តឱ្យកម្មករជៀរជ័រកៅស៊ូខ្លះក្នុងតម្លៃ១កញ្ចប់ពី ២០.០០០ (ពីរម៉ឺន) រៀល ទៅ ២០០.០០០ (ម្ភៃម៉ឺន) រៀល។ ស្រាប់តែនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ មានគេទាក់ទងខ្លួនដើម្បីទិញថ្នាំញៀនពីចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) រៀល ហើយនៅពេលខ្លួន យកថ្នាំញៀនទៅឱ្យគេក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនបានចាប់ផ្តើមលក់ថ្នាំញៀនឱ្យកម្មករជៀរជ័រកៅស៊ូចាប់តាំងពីអំឡុងខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃត្រូវបានឃាត់ខ្លួន។ នៅពេលដែលសមត្ថកិច្ចឃាត់ខ្លួនបានដកហូត ម្សៅក្រាមពណ៌សថ្លាសង្ស័យជាសារធាតុញៀនចំនួន ១៨កញ្ចប់ (កញ្ចប់ធំចំនួន០២ កញ្ចប់តូច ចំនួន១៦) ទម្ងន់ ១៧,២២ (ដប់ប្រាំពីរក្បៀសម្ភៃពីរ) ក្រាម, ទូរស័ព្ទចំនួន ០១ គ្រឿងម៉ាកណូគាចុចពិល, ម៉ូតូម៉ាករ៉េវពណ៌ខ្មៅអត់ស្លាកលេខ ចំនួន ០១គ្រឿង, និងសម្ភារៈសម្រាប់វេចខ្ចប់គ្រឿងញៀនមួយចំនួន។

-តាមចម្លើយមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted]គឹមលេង បានឆ្លើយនាពេលសវនាការថា កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១៧ និង ០០នាទី នៅចំណុច ស្ពានអូរទឹកថ្លា ភូមិបង្កើតាំងរើន ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ កម្លាំងមន្ទីរស្រាវជ្រាវ និងបង្ក្រាបបទល្មើសនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកំពង់ធំ បានសហការជាមួយកម្លាំងកងរាជអាវុធហត្ថស្រុកបារាយណ៍ និងកម្លាំងកងរាជអាវុធហត្ថស្រុកសន្ទុក បានបង្ក្រាបបទល្មើសគ្រឿងញៀន ដោយបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted]សុខខេង ហៅ កំរី ភេទប្រុស អាយុ៣៦ឆ្នាំ។ ជនត្រូវចោទឈ្មោះ [redacted]សុខខេង ហៅ កំរី ភេទប្រុស អាយុ៣៦ឆ្នាំ បានទាក់ទងទិញថ្នាំញៀនតាមទូរសព្ទពីអ្នកលក់មិនស្គាល់ឈ្មោះដោយទិញម្តងៗចន្លោះពី ៣០០.០០០ (សាមសិបម៉ឺន) រៀល ទៅ ១.២០០.០០០ (មួយលានពីរសែន) រៀល។ ពេលបានថ្នាំញៀនជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី បានយកថ្នាំញៀន ទុកប្រើប្រាស់ខ្លះ និងរំលែកលក់បន្តឱ្យកម្មករចៀរជ័រកៅស៊ូក្នុងតម្លៃ១កញ្ចប់ ពី ២០.០០០ (ពីរម៉ឺន) រៀល ទៅ ២០០.០០០ (ម្ភៃម៉ឺន) រៀល។ នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣ មានគេទាក់ទងទិញថ្នាំញៀនពីជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី ចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) រៀល ហើយនៅពេលជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី យកថ្នាំញៀនទៅឱ្យអ្នកទិញក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការពិភាក្សាដេញដោលក្នុងអង្គសវនាការ ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយមន្ត្រីនគរបាលយុត្តិធម៌ និងបានពិនិត្យភស្តុតាងផ្សេងៗនៅក្នុងសំណុំរឿង ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដូចនេះ តំណាងអយ្យការប្តឹងសុំៈ តុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី ភេទប្រុស អាយុ៣៦ឆ្នាំ ពីបទៈ "ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅចំណុចស្ពានអូរទឹកថ្លា ភូមិបង្កីតាំងរ៉ែន ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១៧ និង ០០នាទី បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២។ ហេតុដូច្នេះ តំណាងអយ្យការស្នើសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ៤២១/២០២៣ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣ ទុកនៅដដែល និងស្នើសុំឱ្យតុលាការសម្រេចតាមច្បាប់។



Scanned with CamScanner

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការពិភាក្សាដេញដោលក្នុងអង្គសវនាការ ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយមន្ត្រីនគរបាលយុត្តិធម៌ និងបានពិនិត្យកស្តុតាងផ្សេងៗនៅក្នុងសំណុំរឿង ឃើញថា កូនក្តីឈ្មោះ [redacted] សុខខេង ហៅ កំរី ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន។ ប៉ុន្តែ កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពជូនតុលាការ និងមិនបានផ្តល់ផលលំបាកក្នុងនីតិវិធីរបស់តុលាការទេ ហើយកូនក្តីរបស់ខ្លួនជាមេគ្រួសារ ត្រូវស្វែងរកប្រាក់ដើម្បីចិញ្ចឹមជីវភាពក្នុងគ្រួសារ ហើយគ្រឿងញៀនដែលដកហូតពីកូនក្តីខ្លួនមានទម្ងន់ ១៧,២២ក្រាម ប៉ុន្តែតាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៤៣៦៥៦/២៣ ម.ព.អ.ជ.ប.គ.៣ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់ថា បរិមាណសារធាតុសុទ្ធគឺមាន ៧៦.៤៥ភាគរយ តែប៉ុណ្ណោះ។ បើយកទម្ងន់គ្រឿងញៀនទាំងអស់ចែកនិងសារធាតុសុទ្ធឃើញថា មានទម្ងន់ប្រហែលជាង ១៣ក្រាម តែប៉ុណ្ណោះ។ ដូចនេះ ស្នើសុំតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង និងស្នើសុំតុលាការកែប្រែបទចោទពីបទឧក្រិដ្ឋ មកបទមជ្ឈឹមវិញផង។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] សុខខេង សំណូមពរតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ខ្លួនដឹងកំហុសហើយ ខ្លួនសន្យាឈប់ប្រព្រឹត្តខុសច្បាប់ទៀតហើយ។

## តុលាការក្រោយពីបាន

- ស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] សុខខេង
- ស្តាប់ចម្លើយមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] គីមលេង
- ស្តាប់សេចក្តីសន្និដ្ឋានរបស់ តំណាងអយ្យការ
- ស្តាប់សេចក្តីសន្និដ្ឋានរបស់ **មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**
- ស្តាប់សំណូមពរចុងចម្លើយរបស់ជនជាប់ចោទ
- ពិនិត្យកស្តុតាង ឯកសារទាំងអស់ក្នុងសំណុំរឿង
- ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ ពិតជាមានករណី **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចស្ពានអូរទឹកថ្លា ភូមិបង្គីតាំងរ៉ែន ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី ភេទប្រុស អាយុ៣៦ឆ្នាំ ប្រាកដមែន។

២-តាមដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការលេខ៖ ៤២១/២០២៣ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣ និងដីកាដំណោះស្រាយលេខ៖ ៣៦៤៥ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **សុខខេង ហៅ កំរី** ភេទប្រុស អាយុ ៣៦ឆ្នាំ ពីបទ៖ **"ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន"** មកជំនុំជម្រះ។

៣-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សុខខេង បានឆ្លើយនាពេលសនៅការថា ខ្លួនទទួលស្គាល់ការចោទប្រកាន់របស់តំណាងអយ្យការ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនរយៈពេល៣ឆ្នាំមកហើយ។ ខ្លួនមិនដែលធ្លាប់ទទួលវិធានការបន្សាបថ្នាំញៀននោះទេ។ នៅអំឡុងដើមឆ្នាំ២០២៣ ខ្លួនបានស្គាល់លេខទូរស័ព្ទរបស់អ្នកលក់ថ្នាំញៀនមិនស្គាល់ឈ្មោះម្នាក់ នៅទួលពន្លៃ ខេត្តត្បូងឃ្មុំ។ ខ្លួនបានទាក់ទង

ទិញថ្នាំញៀនតាមទូរស័ព្ទពីអ្នកលក់នេះបានចំនួន ៦ដង ដោយទិញម្តងៗចន្លោះពី ៣០០.០០០ (សាមសិបម៉ឺន) រៀល ទៅ ១.២០០.០០០ (មួយលានពីរសែន) រៀល ពេលទិញថ្នាំញៀនរាល់ដងខ្លួន បានជិះម៉ូតូទៅយកថ្នាំញៀននៅជិតទួលពន្លៃខេត្តត្បូងឃ្មុំ។ ពេលបានថ្នាំញៀនខ្លួនបានយកថ្នាំ ញៀនទុកប្រើប្រាស់ខ្លះ និងវែលកលក់បន្តឱ្យកម្មករជៀរជ័រកៅស៊ូខ្លះក្នុងតម្លៃ១កញ្ចប់ពី ២០.០០០ (ពីរម៉ឺន) រៀល ទៅ ២០០.០០០ (ម្ភៃម៉ឺន) រៀល។ ស្រាប់តែនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ មានគេទាក់ទងខ្លួនដើម្បីទិញថ្នាំញៀនពីចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) រៀល ហើយនៅពេលខ្លួនយកថ្នាំញៀនទៅឱ្យគេក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនបានចាប់ផ្តើមលក់ថ្នាំញៀនឱ្យកម្មករជៀរជ័រកៅស៊ូចាប់តាំងពីអំឡុងខែមករា ឆ្នាំ២០២៣ ហូតដល់ថ្ងៃត្រូវបានឃាត់ខ្លួន។ នៅពេលដែលសមត្ថកិច្ចឃាត់ខ្លួនបានដកហូតម្សៅក្រាមពណ៌សថ្លាសង្ស័យជាសារធាតុញៀនចំនួន ១៨កញ្ចប់ (កញ្ចប់ធំចំនួន០២ កញ្ចប់តូច ចំនួន១៦) ទម្ងន់ ១៧,២២ (ដប់ ប្រាំពីរ ក្បៀសម្ភៃពីរ) ក្រាម, ទូរស័ព្ទចំនួន ០១ គ្រឿងម៉ាកណូគាចុចពិល, ម៉ូតូម៉ាកវេវពណ៌ខ្មៅអត់ស្លាកលេខ ចំនួន ០១គ្រឿង, និងសម្ភារៈសម្រាប់វេចខ្ចប់គ្រឿងញៀនមួយចំនួន។ អាចឱ្យតុលាការជឿបានថាជនជាប់ចោទឈ្មោះ [redacted] សុខខេង ភេទប្រុស អាយុ៣៦ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រាកដមែន អាចឱ្យតុលាការពិចារណាបាន។

៤-តាមចម្លើយមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] គឹមលេង បានឆ្លើយនាពេលសវនាការថា កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១៧ និង ០០នាទី នៅចំណុចស្ពានអូរទឹកថ្លា ភូមិបង្កើតាំងវេីន ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ កម្លាំងមន្ទីរស្រាវជ្រាវ និងបង្ក្រាបបទល្មើសនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកំពង់ធំ បានសហការជាមួយកម្លាំងកងរាជអាវុធហត្ថស្រុកបារាយណ៍ និងកម្លាំងកងរាជអាវុធហត្ថស្រុកសន្ទុកបានបង្ក្រាបបទល្មើសគ្រឿងញៀន ដោយបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី ភេទប្រុស អាយុ៣៦ឆ្នាំ។ ជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី ភេទប្រុស អាយុ៣៦ឆ្នាំ បានទាក់ទងទិញថ្នាំញៀនតាមទូរសព្ទពីអ្នកលក់មិនស្គាល់ឈ្មោះដោយទិញម្តងៗចន្លោះពី ៣០០.០០០ (សាមសិបម៉ឺន) រៀល ទៅ ១.២០០.០០០ (មួយលានពីរសែន) រៀល។ ពេលបានថ្នាំញៀនជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី បានយកថ្នាំញៀន ទុកប្រើប្រាស់ខ្លះ និងវែលកលក់បន្តឱ្យកម្មករចៀរជ័រកៅស៊ូក្នុងតម្លៃ ១កញ្ចប់ ពី ២០.០០០ (ពីរម៉ឺន) រៀល ទៅ ២០០.០០០ (ម្ភៃម៉ឺន) រៀល។ នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ ២០២៣ មានគេទាក់ទងទិញថ្នាំញៀនពីជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី ចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) រៀល ហើយនៅពេលជាប់ត្រូវចោទឈ្មោះ [redacted] សុខខេង ហៅ កំរី យកថ្នាំញៀនទៅឱ្យអ្នកទិញក៏ត្រូវសមត្ថកិច្ចឃាត់ ខ្លួនតែម្តង។ អាចឱ្យតុលាការជឿបានថាជនជាប់ចោទឈ្មោះ [redacted] **សុខខេង** ហៅ កំរី ភេទប្រុស អាយុ៣៦ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រាកដមែន អាចឱ្យតុលាការពិចារណាបាន។

៥-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុខខេង បានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈសង្គម ដែលច្បាប់បញ្ញត្តិជាបទល្មើស និងត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ **កថាខណ្ឌ៣ និងកថាខណ្ឌ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២។**

៦-ពេលប្រព្រឹត្តបទល្មើសជនជាប់ចោទឈ្មោះ [redacted] សុខខេង ស្ថិតក្នុងស្ថានភាពអាចយល់ដឹងពីអំពើដែលខ្លួនបានប្រព្រឹត្ត ហើយពុំមានលិខិតណាបញ្ជាក់ថា ឈ្មោះ [redacted] សុខខេង មានបញ្ហាវិបល្លាសស្មារតីដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។



Scanned with CamScanner

៧-ពេលប្រព្រឹត្តបទល្មើសជនជាប់ចោទឈ្មោះ [redacted] សុខខេង ជានីតិជនដែលច្បាប់កំណត់ថាមាននីតិភាពក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។ ដោយពេលប្រព្រឹត្តបទល្មើសជនជាប់ចោទមានស្មារតីគ្រប់គ្រាន់។

៨-វត្ថុតាងរួមមាន៖ ម្សៅក្រាមពណ៌សថ្លាសង្ស័យជាសារធាតុញៀនចំនួន ១៨កញ្ចប់ (កញ្ចប់ធំចំនួន ០២ កញ្ចប់តូច ចំនួន១៦) ទម្ងន់ ១៧,២២ (ដប់ប្រាំពីរក្បៀសម្ភៃពីរ) ក្រាម, ទូរស័ព្ទចំនួន ០១ គ្រឿង ម៉ាកណូគាចុចពិល, ម៉ូតូម៉ាកវេវពណ៌ខ្មៅអត់ស្លាកលេខ ចំនួន ០១គ្រឿង, និងសម្ភារៈសម្រាប់វេចខ្ចប់គ្រឿងញៀនមួយចំនួន។

៩-តាមកំណត់ហេតុទទួលស្គាល់វត្ថុតាងចាប់យក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថខេត្តកំពង់ធំ បានដកហូតគ្រឿងញៀនពីឈ្មោះ [redacted] សុខខេង ហៅ កំរី ភេទប្រុស អាយុ៣៦ឆ្នាំ ចំនួន១៨កញ្ចប់ មានទម្ងន់ ១៧,២២ (ដប់ប្រាំពីរក្បៀសម្ភៃពីរ) ក្រាម។ តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ៤៣៦៥៦/២៣ ម.ព.អ.ជ.ប.គ.៣ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់ថា សំណាក់នៅក្នុងកញ្ចប់រក្សាវត្ថុតាងបិទជិត មានហត្ថលេខាគណៈកម្មការ និងស្នាមមេដៃឈ្មោះ [redacted] សុខខេង ជាលទ្ធផល៖ វិជ្ជមាន, វត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន (Metamfetamine) បរិមាណសារធាតុ មេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់គឺ៖ ៧៦,៤៥% (ចិតសិបប្រាំមួយ កណ្ដក់សញ្ញា សែសិបប្រាំ ភាគរយ)។ តាមការគណនាទម្ងន់គ្រឿងញៀនមាន ១៧,២២ ក្រាម ដែលមានសារធាតុសុទ្ធចំនួន ១៣,១៦ ក្រាម។ ដូចនេះ គប្បីតុលាការពិចារណាផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ស្ដីពីគ្រឿងញៀន។

១០-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា ឆ្លងតាមការពិភាក្សាដេញដោលក្នុងអង្គសវនាការ ក្រោយពីបានស្ដាប់ចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយមន្ត្រីនគរបាលយុត្តិធម៌ និងបានពិនិត្យភស្តុ-តាងផ្សេងៗនៅក្នុងសំណុំរឿង ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដូចនេះ តំណាងអយ្យការប្ដឹងសុំ តុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី ភេទប្រុស អាយុ៣៦ឆ្នាំ ពីបទ៖ "ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅចំណុចស្ពានអូរទឹកថ្លា ភូមិបង្គីតាំងរ៉ែន ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១៧ និង ០០នាទី បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២។ ហេតុដូច្នេះ តំណាងអយ្យការស្នើសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ៤២១/២០២៣ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣ ទុកនៅដដែល និងស្នើសុំឱ្យតុលាការសម្រេចតាមច្បាប់, អាចឱ្យតុលាការពិចារណាបាន។

១១-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា ឆ្លងតាមការពិភាក្សាដេញដោលក្នុងអង្គសវនាការ ក្រោយពីបានស្ដាប់ចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយមន្ត្រីនគរបាលយុត្តិធម៌ និងបានពិនិត្យភស្តុតាងផ្សេងៗនៅក្នុងសំណុំរឿង ឃើញថា កូនក្ដីឈ្មោះ [redacted] សុខខេង ហៅ កំរី ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន។ ប៉ុន្តែ កូនក្ដីរបស់ខ្លួនបានឆ្លើយសារភាពជូនតុលាការ និងមិនបានផ្ដល់ផលលំបាកក្នុងនីតិវិធីរបស់តុលាការទេ ហើយកូនក្ដីរបស់ខ្លួនជាមេគ្រួសារ ត្រូវស្វែងរកប្រាក់ដើម្បីចិញ្ចឹមជីវភាពក្នុងគ្រួសារ ហើយគ្រឿងញៀនដែលដកហូតពីកូនក្ដីខ្លួនមានទម្ងន់ ១៧,២២ក្រាម ប៉ុន្តែតាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ៤៣៦៥៦/២៣ ម.ព.អ.ជ.ប.គ.៣ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់ថា បរិមាណសារធាតុសុទ្ធគឺមាន ៧៦.៤៥ភាគរយ



Scanned with CamScanner

តែប៉ុណ្ណោះ។ បើយកទម្ងន់គ្រឿងញៀនទាំងអស់ចែកនិងសារជាតុសុទ្ធឃើញថា មានទម្ងន់ប្រហែលជាង ១៣ក្រាម តែប៉ុណ្ណោះ។ ដូចនេះ ស្នើសុំតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង និងស្នើសុំតុលាការកែប្រែបទចោទពីបទឧក្រិដ្ឋ មកបទមជ្ឈិមវិញផង។

១២-ជនជាប់ចោទឈ្មោះ [redacted] សុខខេង សំណូមពរតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ខ្លួនដឹងកំហុសហើយ ខ្លួនសន្យាឈប់ប្រព្រឹត្តខុសច្បាប់ទៀតហើយ, អាចឱ្យតុលាការពិចារណាបាន។

១៣-ក្រោយពីបានធ្វើការគណនាដោយយោងតាមគ្រឿងញៀនរបស់ឈ្មោះ [redacted] សុខខេង ដែលមានទម្ងន់ចំនួន ១៧,២២ (ដប់ប្រាំពីរ ក្បៀស ម្ភៃពីរ) ក្រាម និងតាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៤៣៦៥៦/២៣ ម.ព.អ.ជ.ប.គ.៣ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលលទ្ធផល វិជ្ជមាន វត្ថុមានសារជាតុញៀន មេតំហ្វេតាមីន បរិមាណសារជាតុគិតជាភាគរយ នៃទម្ងន់ គឺ ៧៦,៤៥ (ចិតសិបប្រាំមួយ កណ្តក់សញ្ញា សែសិបប្រាំ) ភាគរយ នៃទម្ងន់ ១៧,២២ ក្រាម ស្មើនឹង ១៣,១៦ (ដប់បី ក្បៀស ដប់ប្រាំមួយ) ក្រាម។ តាមការពិនិត្យជាតុសុទ្ធទាំងអស់លើចំនួនគ្រឿងញៀន ១៧,២២ក្រាម គឺមានជាតុសុទ្ធចំនួន ១៣,១៦ក្រាម ដែលមិនចូលក្នុងមាត្រា ៤០ កថាខណ្ឌ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលជាតុសុទ្ធនៃមេតំហ្វេតាមីន ចាប់ពី ១៥ក្រាម រហូតដល់ក្រោម ៨០ក្រាម។ ហេតុនេះសារជាតុសុទ្ធ មានចំនួនសរុប ១៣,១៦ (ដប់បី ក្បៀស ប្រាំមួយ) ក្រាម។ ផ្អែកតាមមាត្រា ៤០ កថាខណ្ឌទី៣ និងកថាខណ្ឌទី៥ ត្រង់ចំណុចទី៦ ចែងថា អំហ្វេតាមីន មេតំហ្វេតាមីន ឬ អ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ១៥ (ដប់ប្រាំ) ក្រាម រហូតដល់ក្រោម ៨០ (ប៉ែតសិប) ក្រាម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល។ ប៉ុន្តែ ចំពោះជាតុសុទ្ធសរុបនៃគ្រឿងញៀនរបស់ឈ្មោះ [redacted] សុខខេង មានចំនួនតែ ១៣.១៦ (ដប់បី ក្បៀស ដប់ប្រាំមួយ) ក្រាម តែប៉ុណ្ណោះ ដូចនេះ គប្បី តុលាការធ្វើការកែប្រែការចោទប្រកាន់ពីកថាខណ្ឌ៥ មកជា កថាខណ្ឌ៤ វិញ។

១៤-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី ភេទប្រុស អាយុ៣៦ឆ្នាំ ពីបទ៖ "ជួញដូរដោយខុសច្បាប់នូវសារជាតុញៀន" ប្រព្រឹត្តនៅចំណុចស្ពានអូរទឹកថ្លា ភូមិបង្កីតាំងរ៉ែន ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១៧ និង ០០នាទី បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២។

## <u>សេចក្តីសម្រេច</u>

## <u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>

១/-ប្តូរកថាខណ្ឌនៃមាត្រា ៤០ នៃបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី ភេទប្រុស អាយុ៣៦ឆ្នាំ ពីមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកជាមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនវិញ។

២/-<u>ផ្តន្ទាទោសជនជាប់ចោទ</u>ឈ្មោះ [redacted] សុខខេង ហៅ កំរី ភេទប្រុស អាយុ៣៦ឆ្នាំ (ដែលមានអត្តសញ្ញាណដូចខាងលើ) ពីបទ៖ "ជួញដូរដោយខុសច្បាប់នូវសារជាតុញៀន" ប្រព្រឹត្តនៅចំណុចស្ពានអូរទឹកថ្លា ភូមិបង្កីតាំងរ៉ែន ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១៧ និង ០០នាទី តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន



Scanned with CamScanner

ឆ្នាំ២០១២ ដាក់ពន្ធនាគារកំណត់រយៈពេល ៤ (បួន) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល បង់ចូលថវិការដ្ឋ។

៣/-វត្ថុតាងរួមមាន៖

ក-ម្សៅក្រាមពណ៌សថ្លាជាសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន (Metamfetamine) ចំនួន១៨ កញ្ចប់ ទម្ងន់ ១៧,២២ក្រាម ដែលមានបរិមាណជាតុសុទ្ធ ចំនួន ១៣,១៦ ក្រាម និងសម្ភារៈសម្រាប់វេចខ្ចប់គ្រឿងញៀនមួយចំនួន រឹបអូសបំផ្លាញចោល។

ខ-ទូរស័ព្ទចំនួន ០១ គ្រឿងម៉ាកណូគាចុចពិល, ម៉ូតូម៉ាកវេវពណ៌ខ្មៅអត់ស្លាកលេខ ចំនួន ០១ គ្រឿង រឹបអូសទុកជាទ្រព្យសម្បត្តិរដ្ឋ។

សាលក្រមនេះ បានធ្វើការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ និងបានប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុខខេង ហៅ កំរី។

ភាគីដែលច្បាប់ផ្តល់សិទ្ធិឱ្យ អាចប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់៕

ថ្ងៃពុធ ៥កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ខេត្តកំពង់ធំ, ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សា**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៥កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ខេត្តកំពង់ធំ, ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner